**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ក្រុមប្រឹក្សារដ្ឋមន្ត្រី**
លេខៈ៧៣ ស រ ច

# សេចក្តីសំរេច
# ស្តីពីពេលម៉ោងធ្វើការ និង ពេលឈប់សំរាករបស់ កម្មាភិបាល បុគ្គលិក កម្មករ

-បានឃើញអង្គការចាត់តាំង និង សកម្មភាព របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រកាសផ្សាយតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០-០២-៨២ នៃ ក្រុមប្រឹក្សារដ្ឋ

-អនុលោមតាមសំណូមពរ របស់រដ្ឋមន្ត្រីក្រសួងផែនការ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី សំរេច

**I-ថេរៈវេលាធ្វើការៈ**

១-ក្នុងក្រសួងមន្ទីរ សហគ្រាសរដ្ឋ ថេរៈវេលាធ្វើការពេញលេញ នៃកម្មាភិបាល បុគ្គលិក កម្មករទាំងពីរភេទ គឺ ប្រាំបីម៉ោង "៨ម៉ោង" ក្នុងមួយថ្ងៃ។

ក-ចំពោះក្រសួង មន្ទីរ "រដ្ឋបាល" ពីមជ្ឈឹមរហូតដល់ក្រុង និង ខេត្តៈ

-ព្រឹក ពីម៉ោងប្រាំពី "៧" ដល់ម៉ោង ដប់មួយនិងសាមសិបនាទី "១១.៣០"។

-ល្ងាច ពីម៉ោង ដប់បួន "១៤" ដល់ម៉ោង ដប់ប្រាំពីរនិងសាមសិបនាទី "១៧.៣០"។

ខ-ចំពោះសហគ្រាស រោងចក្រ អាគារលក់ដូរ ដែលនៅចំណុះក្រសួងមជ្ឈឹម ឬ ចំណុះក្រុង និងខេត្ត របៀបចែកពេលវេលាធ្វើការ ត្រូវកំរិតដោយក្រសួង ក្រុង និងខេត្ត ដែលគ្រប់គ្រងសំរាប់កន្លែងធ្វើការផ្សេងៗ តាមប្រភេទនៃសកម្មភាព និងរបៀបរៀបចំរបស់ខ្លួន។

២-ក្នុងករណីពិសេស ដែលតម្រូវអោយកម្មាភិបាល បុគ្គលិក កម្មករ ធ្វើការខុសពីម៉ោងកំណត់ដូចខាងលើ កម្មាភិបាល បុគ្គលិក កម្មករ ទាំងអស់នោះត្រូវបានឈប់សំរាកនៅថ្ងៃបន្ទាប់ ដើម្បីទូទាត់ស្មើគ្នានឹងពេលសំរាកដែលបានអាក់ខាន។ ក្នុងករណីដែលការឈប់សំរាក ទូទាត់មិនអាចធ្វើបានកម្មាភិបាល បុគ្គលិក កម្មករ នឹងត្រូវបានប្រាក់បន្ថែមតាមអត្រា ដែលតំលើងមួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

**II-ការឈប់សំរាកប្រចាំសប្តាហ៍ៈ**

១-ក្នុងមួយសប្តាហ៍ កម្មាភិបាល បុគ្គលិក កម្មករ ត្រូវបានសំរាកមួយថ្ងៃដោយមានប្រាក់បំណាច់ប្រចាំជីវភាព។ តាមធម្មតា ថ្ងៃឈប់សំរាកនេះ គឺ ថ្ងៃអាទិត្យ ។

ក្នុងករណីធ្វើផលិតកម្ម តម្រូវអោយធ្វើការថ្ងៃអាទិត្យ ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ នឹងកំណត់ ថ្ងៃណាមួយក្នុងសប្តាហ៍នេះ។

ក្នុងករណីពិសេស បើថ្ងៃឈប់សំរាកនេះមិនអាចអនុវត្តន៍បានក្នុងសប្តាហ៍នេះទេនោះ កម្មាភិបាល បុគ្គលិក កម្មករ នឹងត្រូវបានប្រាក់បន្ថែមតាមអត្រាដែលតំលើងមួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

២-ក្រសួង មន្ទីរ ខេត្ត ក្រុង អាចកំណត់អោយអង្គភាពទាំងឡាយដូចខាងក្រោមនេះឈប់សំរាកប្រចាំសប្តាហ៍ ក្រៅពីថ្ងៃអាទិត្យ។

-សណ្ឋាគារ ភោជនីយដ្ឋាន

-មន្ទីរពេទ្យ ឱសថាល័យ ឱសថស្ថាន

-សារពត៌មាន ឃោសនាការ និង ទស្សនីយភាព សារមន្ទីរ និង ពិពរណ៏

-សហគ្រាសដឹកជញ្ជូនជើងគោក ទឹក អាកាស

-ក្រុមហ៊ុនអគ្គីសនី , រដ្ឋាករទឹក

-រោងចក្រនានាដែលផលិតជាប់រហូត ។ល។

## III-ថ្ងៃឈប់បុណ្យ ដែលត្រូវមានប្រាក់បំណាច់ប្រចាំជីវភាព:

១-ថ្ងៃឈប់បុណ្យ ដែលមានប្រាក់បំណាច់ប្រចាំជីវភាពគឺ:

-បុណ្យជាតិ ៧ មករា គឺថ្ងៃទី ៦, ៧ មករា......ពីរថ្ងៃ "២ថ្ងៃ"

-បុណ្យចូលឆ្នាំ គឺ ថ្ងៃទី ១៣,១៤ និង១៥ មេសា......បីថ្ងៃ "៣ថ្ងៃ"

-បុណ្យជ័យជំនះ ១៧ មេសា......មួយថ្ងៃ "១ថ្ងៃ"

-បុណ្យទិវាពលកម្មអន្តរជាតិ គឺ ថ្ងៃទី ១ ឧសភា......មួយថ្ងៃ "១ថ្ងៃ"

-បុណ្យគោរពវិញ្ញាណក្ខ័ន្ធ គឺថ្ងៃទី ខែដាច់ ខែភទ្របទ ផ្ទែកចន្ទគតិ "ភ្ជុំបិណ្ឌ"......................................................មួយថ្ងៃ "១ថ្ងៃ"

ចំពោះកងទ័ព គេអាចរៀបចំពិធីបុណ្យរំលឹកកំណើតកងទ័ព នៅថ្ងៃទី ១៩ ខែ មិថុនា។

២-ថ្ងៃបុណ្យដែលត្រូវឈប់មានប្រាក់បំណាច់ប្រចាំជីវភាពទាំងឡាយខាងលើនេះ មិនត្រូវគិតដើម្បីផ្តាច់ពេលឈប់សំរាកប្រចាំឆ្នាំមានប្រាក់បំណាច់នោះទេ។ បើចាំបាច់ត្រូវធ្វើការក្នុងពេលថ្ងៃបុណ្យ គឺ ត្រូវបានឈប់សំរាកទូទាត់នៅថ្ងៃបន្ទាប់បើក្នុងករណីដែលមិនអាចគិតគូរ ទូទាត់បាន កម្មាភិបាល បុគ្គលិក កម្មករទាំងនោះត្រូវបានប្រាក់បន្ថែម តាមអត្រាតំលើង មួយរយភាគរយ "១០០%" លើកំរិតប្រាក់បំណាច់ប្រចាំជីវភាពប្រចាំថ្ងៃ។

## IV -ការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ បំណាច់ប្រចាំជីវភាព:

១-កម្មាភិបាល បុគ្គលិក កម្មករ ទាំងអស់ ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ មានប្រាក់បំណាច់ប្រចាំជីវភាព ចំនួន ដប់ប្រាំថ្ងៃ "១៥ថ្ងៃ" ក្នុងមួយឆ្នាំ ក្រោយពីបានបំរើក្រសួងបានមួយឆ្នាំរួចមក។

ក្រោយពីបានបញ្ចប់កម្មវិធីសិក្សាក្នុងឆ្នាំនិមួយៗ គ្រូបង្រៀន និង សាស្ត្រាចារ្យត្រូវបានឈប់សំរាកចំនួន ពីរខែ "២ ខែ"។

២-ការឈប់សំរាកប្រចាំឆ្នាំ ដូចបានកំណត់ខាងលើ មិនត្រូវគិតការឈប់សំរាកដោយបណ្តាលមកពីជម្ងឺដែលមានរយៈពេលតិចជាងបីខែក្នុង ១ឆ្នាំ ឬការឈប់សំរាកដែលបានកំណត់រួចហើយ នៃស្ត្រីឆ្លងទន្លេជាកម្មាភិបាល បុគ្គលិក កម្មករ រដ្ឋនោះទេ។

## V -ការឈប់សំរាកពិសេស

កម្មាភិបាល បុគ្គលិក កម្មករវដ្ឋ ដែលបានឈប់សំរាកប្រចាំឆ្នាំរួចហើយតែនៅមាន ករណីផ្ទាល់ខ្លួន ដូចជាស្លាប់ឪពុក ម្តាយ ប្រពន្ធ ប្តី កូន និងរៀបមង្គលការកូន ឬសាមីខ្លួនផ្ទាល់ អាចនឹងស្នើសុំឈប់សំរាកពិសេស ដែលកំណត់ដូចខាងក្រោមនេះ

១-ពី ១ ថ្ងៃ ដល់ ៣ថ្ងៃ ត្រូវមានការយល់ព្រមពីប្រធាន ឬអនុប្រធាន នាយកដ្ឋាន ឬ មុខងារប្រហាក់ប្រហែលពីប្រធាននិង អនុប្រធាន មន្ទីរ ក្រុង ឬ ខេត្ត ឬ មុខងារប្រហាក់ប្រហែលពីប្រធាន និង អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក។

២-ពី ៤ ថ្ងៃ ដល់ ៧ថ្ងៃត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ឬ អនុរដ្ឋមន្ត្រីឬ ថ្នាក់ប្រហាក់ប្រហែលពីប្រធាន ឬ អនុប្រធាន នៃគណៈកម្មាធិការប្រជាជនបដិវត្តនៃ ក្រុង និង ខេត្ត។

## VI -ការអនុវត្តន៍

១-សេចក្តីសំរេចនេះមាន ប្រសិទ្ធិភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដើម្បីជំនួសបទបញ្ជាលើកមុន។

រដ្ឋមន្ត្រី និង ប្រធានមន្ទីរគ្រប់ក្រសួង គ្រប់គណៈកម្មាធិការប្រជាជនបដិវត្តន៍ ក្រុង និង ខេត្ត ត្រូវទទួលភារៈរៀងៗខ្លួន ដើម្បីអនុវត្តន៍តាម សេចក្តីសំរេចនេះ។

២-រដ្ឋមន្ត្រី ក្រសួង ផែនការ មានភារៈទទួលខុសត្រូវក្នុងការណែនាំ និង ត្រួតពិនិត្យ ការអនុវត្តន៍សេចក្តីសំរេចនេះ នៅគ្រប់ក្រសួង មន្ទីរ គ្រប់ក្រុង និងខេត្ត។

ភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨២
ជ- ក្រុមប្រឹក្សារដ្ឋមន្ត្រី
ប្រធាន
ហត្ថលេខា និង ត្រា
**ចាន់ ស៊ី**

**កន្លែងទទួលៈ**

- រដ្ឋសភា
-ក្រុមប្រឹក្សារដ្ឋ
-គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈឹម
-វិទ្យុសម្លេងប្រជាជនកម្ពុជា
"ដើម្បីផ្សព្វផ្សាយ"
-គ្រប់ក្រុងនិង ខេត្ត
-ឯកសារ

លេខៈ ៦០ ចល
បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២១ ខែ ៥ ឆ្នាំ ១៩៨២
ជ.រដ្ឋមន្ត្រី ឧទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
ឧបការី
ហត្ថលេខា និង ត្រា
**ម្យាស់ លាស់**

ក្រុមប្រឹក្សារដ្ឋមន្ត្រី
ក្រសួងផែនការ
លេខៈ៤៦ ផក-៣១-៥-៨២
បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ជ.រដ្ឋមន្ត្រីក្រសួងផែនការ
**អនុរដ្ឋមន្ត្រី**